# របាយការណ៍កិច្ចប្រជុំ
# ពិនិត្យមើលលទ្ធផលការងារ ០៦ខែដើមឆ្នាំ២០១៧
# របស់ក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់
# ប្រយុទ្ធនឹងជំងឺអេដស៍



**ថ្ងៃទី១២-១៣ ខែតុលា ឆ្នាំ២០១៧**

**ខេត្តបាត់ដំបង**

នៅព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ នេះ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំពិនិត្យមើលលទ្ធផលការងារ០៦ខែដើមឆ្នាំ២០១៧ របស់ក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់។ សមាសភាពចូលរួមកិច្ចប្រជុំនេះ មានគណៈកម្មាធិការ និងប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តបាត់ដំបង ព្រមទាំងធ្វើការពិភាក្សាអំពីបញ្ហារបស់ក្រុមប្រឈមមុខខ្ពស់ និងផ្តល់ជាអនុសាសន៍ សម្រាប់ការអនុវត្តការងារអេដស៍នៅថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ជាពិសេសអាជ្ញាធរមូលដ្ឋានមានដូចជា ប៉ូលីស កងរាជអាវុធហត្ថ និងដៃគូពាក់ព័ន្ធប្រមាណជាង ៤០នាក់ ។

**១. គោលបំណង**

- ពិនិត្យ និងពិភាក្សាលើលទ្ធផលដែលសម្រេចបានក្នុងកម្មវិធីបង្ការ ថែទាំ និងព្យាបាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងខេត្តបាត់ដំបង។
- ពង្រឹងការចូលរួម និងគាំទ្ររបស់ភាគីពាក់ព័ន្ធក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍
- ផ្សព្វផ្សាយពីច្បាប់ គោលការណ៍ណែនាំ និងសេចក្តីប្រកាសនានា ក្នុងការគាំទ្រកម្មវិធីអេដស៍ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**២. ការពិភាក្សា**

- សកម្មភាពដែលបានអនុវត្តកន្លងមក
- តំបន់គ្របដណ្តប់ដែលបានធ្វើសកម្មភាពការងារ និងក្រុមគោលដៅតាមប្រភេទសេវា
- សមិទ្ធផលដែលសម្រេចបាន
- បញ្ហាប្រឈម។

❖ **សកម្មភាពដែលបានអនុវត្តកន្លងមក**

កម្មវិធីងបង្ការ ថែទាំ និងគាំទ្រ ដល់ស្ត្រីបម្រើសេវាកម្សាន្ត

- បានធ្វើវគ្គបណ្តុះបណ្តាលដល់បុគ្គលិក និងអ្នកអប់រំផ្ទាល់ ទៅដល់ក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់។
- ចុះធ្វើផែនការទៅលើក្រុមដែលជាគោលដៅរួមមាន ម្ចាស់គ្រឹះស្ថានសេវាកម្សាន្តសប្បាយ និងមេកាហាងមួយចំនួន។
- ចុះជួបជាមួយក្រុមដែលជាគោលដៅតាមពេលវេលាសមស្រប ដើម្បីងាយស្រួលជួបពួកគាត់ និងបង្កលក្ខណៈសមស្របសម្រាប់ការផ្តល់ព័ត៌មានបានពេញលេញ និងច្បាស់លាស់។
- បានសម្ភាសជាមួយពួកគាត់ ជារួមយើងអាចវាយតម្លៃអំពីកម្រិតនៃការប្រឈម ការផ្តល់ការអប់រំជាប្រព័ន្ធ ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងស្វាយ ព្រមទាំងចែកស្រោមអនាម័យជូនពួកគាត់ដោយឥតគិតថ្លៃ ដើម្បីបង្ការកុំឱ្យឆ្លងមេរោគអេដស៍ និងជំងឺផ្សេងៗ។

- ការសម្រួលមធ្យោបាយដោយបញ្ជូនក្រុមស្ត្រីដែលគិតថា មានបញ្ហាប្រឈមទៅទទួលសេវាព្យាបាលនៅមណ្ឌលសុខភាព ឬអង្គការដែលជាដៃគូ។

❖ **តំបន់គ្របដណ្តប់ដែលបានធ្វើសកម្មភាពការងារ និងក្រុមគោលដៅតាមប្រភេទសេវា**

- នៅក្នុងខេត្តបាត់ដំបង ក្នុងមន្ទីរពេទ្យប្រតិបត្តិស្រុកសំពៅលូន មានក្រុមគោលដៅតាមផែនការចំនួន១៧៨២នាក់ និងជាក់ស្តែងចំនួន១៨៨៨នាក់ ដែលក្នុងស្រុកសំពៅលូនតាមផែនការនេះចំនួន២១១នាក់ និងជាក់ស្តែងចំនួន២៩០នាក់ ក្នុងចំណោមប្រជាជនប្រឈមសរុប៤១៧១នាក់។
- ក្រុមដែលជាគោលដៅតាមប្រភេទសេវារួមមាន ស្ត្រីបម្រើសេវាតាមខារ៉ាអូខេចំនួន៨៦០នាក់ ស្មើនឹង៤០% ស្ត្រីបម្រើសេវាតាមភោជនីយដ្ឋានចំនួន៨០២នាក់ ស្មើនឹង៣៧% ស្ត្រីបម្រើតាមហាងម៉ាស្សាចំនួន៣០៨នាក់ ស្មើនឹង១៤% ស្ត្រីឯករាជចំនួន១៤៩នាក់ ស្មើនឹង៥% និងស្ត្រីបម្រើសេវាលក់ស្រាបៀរចំនួន៥៦នាក់ ស្មើនឹង៤% គិតត្រឹមខែមករា ដល់ខែមិថុនា ឆ្នាំ២០១៧។

❖ **សមិទ្ធផលដែលសម្រេចបាន**

- បានរៀបចំវគ្គបណ្តុះបណ្តាលដល់ក្រុមស្ត្រីថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលជាក្រុមគោលដៅ។
- បានចែកស្រោមអនាម័យជូនដល់ក្រុមស្ត្រីបម្រើសេវាតាមភោជនីយដ្ឋាន ស្ត្រីបម្រើសេវាតាមខារ៉ាអូខេ ស្ត្រីបម្រើតាមហាងម៉ាស្សា ស្ត្រីឯករាជ និងស្ត្រីបម្រើសេវាលក់ស្រាបៀរ ដែលជាក្រុមប្រឈមដោយឥតគិតថ្លៃ ដើម្បីបង្ការកុំឱ្យឆ្លងមេរោគអេដស៍ និងជំងឺផ្សេងៗ។
- បានផ្តល់ការអប់រំជាប្រព័ន្ធ ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងការរក្សាការសម្ងាត់ជូនពួកគាត់។
- លទ្ធផលធ្វើតេស្តឈាមចុងម្រាមដៃរកមេរោគអេដស៍ បានចំនួន១៧៩៤ នាក់ ក្នុងចំណោមគម្រោងដែលបានរំពឹងទុកចំនួនសរុប១៨១២នាក់ និងធ្វើតេស្តឈាមរកមេរោគស្វាយ បានចំនួន១២៤០នាក់ ក្នុងចំណោមគម្រោងដែលបានរំពឹងទុកសរុបចំនួន១៨១២នាក់ គិតត្រឹមខែមករា ដល់ខែមិថុនា ឆ្នាំ២០១៧។
- បានធ្វើតេស្តរកមេរោគអេដស៍ (HTC Testing) នៅក្នុងស្រុកចំនួនបីរួមមាន ស្រុកសំពៅលូន ស្រុកថ្មគោល និងស្រុកសង្កែ សរុបចំនួន២២៩៧នាក់ ក្នុង៣ក់កណ្តាលប្រចាំឆ្នាំ២០១៧។
- ផ្សព្វផ្សាយច្បាប់អេដស៍ គោលនយោបាយ៧ចំណុច របស់រាជរដ្ឋាភិបាល គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព គោលការណ៍ប្រើប្រាស់ស្រោមអនាម័យ១០០% និងគតិយុត្តិដែលពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ជាពិសេសក្រុមស្ត្រីដែលជាគោលដៅ។

- ការងារសម្របសម្រួល

– បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមបច្ចេកទេសថ្នាក់ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។

– បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការអនុវត្ត UIC និង IRIR ក្នុងចំណោមអ្នកផ្តល់សេវាថែទាំសុខភាពរបស់ MSM និង TG ។

– បានចូលរួមកិច្ចប្រជុំទិវាអេដស៍ពិភពលោក ឆ្នាំ២០១៧។

❖ បញ្ហាប្រឈម

– ក្រុមស្ត្រីដែលចូលមកថ្មីភាគច្រើនពួកគាត់មានការលាក់លៀមប្រវត្តិរូបរបស់គាត់ ជាហេតុធ្វើឱ្យមានការពិបាកជួបពួកគាត់ ដើម្បីផ្តល់ប្រឹក្សាយោបល់។

– សកម្មភាពមួយចំនួនមិនបានធ្វើទៅតាមគម្រោងដែលបានគ្រោងទុកទេ ដោយសារតែមានការកាត់បន្ថយថវិកាពីម្ចាស់ជំនួយ។

– ស្ត្រីភាគច្រើនទាល់តែមានបញ្ហាសុខភាពធ្ងន់ធ្ងរ ទើបគាត់ស្វែងរកសេវាពិនិត្យព្យាបាល ទាំងនោះ ដោយសារតែពួកគាត់មានការខ្មាស់អៀន ឬដឹងអំពីស្ថានភាពជំងឺហើយតែមិនហ៊ានមកទទួលសេវា។

– ការចុះអប់រំផ្សព្វផ្សាយ ដល់ក្រុមស្ត្រីដែលធ្វើការនៅតាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយមួយចំនួនមានការលំបាកពីព្រោះតែម្ចាស់សេវាទាំងនេះមិនព្រមសហការជាមួយអង្គការដៃគូ និងអាជ្ញាធរមូលដ្ឋាន។

– ការអប់រំមិនបានគ្រប់ទៅតាមផែនការ ដោយសារតែក្រុមគោលដៅមួយចំនួននៅតែមិនចេញមុខ ឬលាក់មុខ។



– ក្រុមគោលដៅចង់បានស្រោមអនាម័យដោយមិនគិតថវិកា (មិនមែនជាការទិញ) ចែកជូនក្រុមស្ត្រីបម្រើសេវាតាមភោជនីយដ្ឋាន ស្ត្រីបម្រើសេវាតាមខារ៉ាអូខេ ស្ត្រីបម្រើតាមហាងម៉ាស្សា ស្ត្រីឯករាជ និងស្ត្រីបម្រើសេវាលក់ស្រាបៀរ ដោយឥតគិតថ្លៃ ដើម្បីបង្ការកុំឱ្យឆ្លងមេរោគអេដស៍ និងជំងឺផ្សេងៗ។

ក្រោយពីបានស្តាប់ និងមើលលទ្ធផលការងារ ០៦ខែដើមឆ្នាំ២០១៧ របស់ក្រុមការងារថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ រួមនឹងបញ្ហាប្រឈមដែលបានកើតឡើងនៅក្នុងខេត្តរួចមក ឯកឧត្តមអគ្គលេខាធិការ បានផ្តល់មតិណែនាំមួយចំនួនដូចខាងក្រោម៖

- អង្គការសង្គមស៊ីវិល ប្រសិនបើមានការលំបាកក្នុងការអនុវត្តការងារ ត្រូវទាក់ទងទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដើម្បីជួយសម្របសម្រួល និងដោះស្រាយនូវបាតុភាពណាមួយដែលកើតមានឡើង។
- អ្នកផ្តល់សេវា អាជ្ញាធរមូលដ្ឋាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ត្រូវស្វែងយល់អំពីទិដ្ឋភាពច្បាប់ទាំងឡាយដែលពាក់ព័ន្ធដូចជាច្បាប់អេដស៍ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដើម្បីងាយស្រួលចូលរួមអប់រំផ្សព្វផ្សាយដល់ក្រុមស្ត្រីដែលប្រឈមមុខខ្ពស់ នៅក្នុងសហគមន៍របស់ខ្លួន។
- អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បន្តអនុវត្តន៍ច្បាប់អេដស៍ និងផ្សព្វផ្សាយការប្រើប្រាស់ស្រោមអនាម័យ១០០% ជូនដល់ស្ត្រីបម្រើការងារនៅតាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយ ដើម្បីឱ្យពួកគាត់យល់ច្បាស់ និងវិធានការផ្លូវច្បាប់ប្រសិនបើរកឃើញថា បុគ្គលណាម្នាក់ដឹងខ្លួនថា មានផ្ទុកមេរោគអេដស៍ហើយមានចេតនាចម្លងដល់អ្នកដទៃ។
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត បន្តការចូលរួមសហការ និងសម្របសម្រួលរាល់ការងារដែលបានកើតមានឡើង និងជំរុញឱ្យម្ចាស់គ្រឹះស្ថានទាំងនោះជួយសម្រួលដល់អង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កបរិយាសគាំទ្រ និងតាមផែនការ។
- អាជ្ញាធរដែនដី ប៉ូលីស កងរាជអាវុធហត្ថ និងដៃគូពាក់ព័ន្ធ បន្តការលើកទឹកចិត្តក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីចូលរួមផ្សព្វផ្សាយ ឬបើកវគ្គបណ្តុះបណ្តាលខ្លី អំពីច្បាប់អេដស៍ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលការណ៍ប្រើប្រាស់ស្រោមអនាម័យ១០០% និងគោលនយោបាយ៧ចំណុចរបស់រដ្ឋាភិបាល ជូនដល់ក្រុមស្ត្រីដែលធ្វើការងារនៅតាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយ។
- បន្តជំរុញពួកគាត់ឱ្យមកធ្វើតេស្តឈាម ដោយបញ្ជាក់ថា រាល់ការធ្វើតេស្តឈាមត្រូវបានរក្សាភាពសម្ងាត់ ហើយការធ្វើតេស្តឈាមរកមេរោគអេដស៍/ជំងឺអេដស៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងមានការយល់ព្រមជាមុនពីសាមីជនផ្ទាល់។
- ការអប់រំ និងការផ្សព្វផ្សាយ គ្រប់ស្ថាប័ន សហគ្រាស សិប្បកម្ម គ្រឹះស្ថានសេវាកម្សាន្តសប្បាយ និងអង្គការជាដៃគូ ចូលរួមផ្សព្វផ្សាយកម្មវិធីអប់រំ ស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅកន្លែងធ្វើការដោយបញ្ចូលទាំងប្រធានបទចំពោះការរក្សាភាពសម្ងាត់ និងឥរិយាបថចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍។ ហាមដាច់ខាតរាល់ការឃោសនា ឬ ការផ្សព្វផ្សាយពាណិជ្ជកម្មដែលអះអាងពីការព្យាបាល ព្រមទាំងវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍

(HIV/AIDS) ដែលផ្ទុយនឹងវិធានការនានារបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងគោលការណ៍បច្ចេកទេសវេជ្ជសាស្ត្រ។

- ស្វែងរកក្រុមគោលដៅ និងតំបន់គ្របដណ្តប់ នៅថ្នាក់មូលដ្ឋាន និងផ្តល់ការគាំពារសង្គម រួមទាំងការព្យាបាលជូនក្រុមស្ត្រីបម្រើសេវាតាមភោជនីយដ្ឋាន ស្ត្រីបម្រើសេវាតាមខារ៉ាអូខេ ស្ត្រីបម្រើតាមហាងម៉ាស្សា ស្ត្រីឯករាជ និងស្ត្រីបម្រើសេវាលក់ស្រាបៀរ បើធ្វើតេស្តឈាមរកឃើញថា វិជ្ជមាន។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ធ្វើការអប់រំផ្សព្វផ្សាយចំណេះដឹងផ្នែកសុខភាពសង្គម ផ្តល់ការគាំទ្រលើសេវាសុខភាពសាធារណៈ និងចូលរួមកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍ ពិសេសស្ត្រី និងកុមារ។
- ពង្រឹង និងលើកកម្ពស់សេវាសុខភាពសម្រាប់ជនក្រីក្រ នៅតាមជនបទនៃប្រទេសកម្ពុជា តាមរយៈដៃគូសហគមន៍ និងអាជ្ញាធរដែនដី។
- ផ្តល់ការគាំទ្រ និងតាមដាននូវគោលការណ៍ណែនាំ ច្បាប់ និងគោលនយោបាយ ស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ដល់ក្រុមប្រជាជនប្រឈមមុខខ្ពស់ ជាពិសេសក្រុមបុរសស្រឡាញ់ និងស្រីស្រស់ ឱ្យមានប្រសិទ្ធភាព។

### ៣-សំណូមពរ

- សុំផ្តល់ការគាំទ្រពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជួយសម្របសម្រួលជាមួយអាជ្ញាធរដែនដី និងម្ចាស់គ្រឹះស្ថានសេវាកម្សាន្តសប្បាយ ដើម្បីឱ្យក្រុមការងារថ្នាក់ក្រោមជាតិ បុរសស្រឡាញ់បុរស និងស្រីស្រស់ ចុះទៅអប់រំផ្សព្វផ្សាយច្បាប់អេដស៍ ផ្តល់ប្រឹក្សាផ្នែកថែទាំសុខភាពជូនក្រុមស្ត្រីប្រឈមមុខខ្ពស់ ឱ្យទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ និងទូលំទូលាយ។
- សូមឱ្យអ្នកពាក់ព័ន្ធទាំងអស់បន្តជួយជំរុញ និងលើកទឹកចិត្តដល់ស្ត្រីក្នុងការទទួលបានសេវាធ្វើតេស្តឈាម។ រាល់ការធ្វើតេស្តឈាមរកមេរោគអេដស៍ គឺរក្សាការសម្ងាត់ និងដោយស្ម័គ្រចិត្ត។



**ចំណុចខ្លាំង**

- មានការគាំទ្រពីគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត។
- មានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំផ្ទាល់ រួមទាំងស្ថាប័ន និងអង្គការពាក់ព័ន្ធមួយចំនួន។
- ការដោះស្រាយនូវបាតុភាពដែលកើតមានឡើងដោយផ្អែកទៅលើគោលការណ៍ច្បាប់ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធប្រកបដោយការសហការ និងមានប្រសិទ្ធភាពខ្ពស់។

**ចំណុចដែលនៅខ្វះខាត**

- អង្គការដែលជាដៃគូពាក់ព័ន្ធមួយចំនួន មិនទាន់មានការសហការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត បានល្អនៅឡើយ។

ធ្វើនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧

**អគ្គលេខាធិការ**

**ឯកឧត្តមវេជ្ជ. តែង គន្ធី**